# រឿង ដំណើរផ្សងព្រេងរបស់ ផេនដាសុភា



# រឿង ដំណើរផ្សងព្រេងរបស់ ផេនដាសុភា





គ្រួសារផេនដាសុភាមានសមាជិកបួននាក់រស់
នៅលើកំពូលភ្នំមួយ។ នៅឯនាយភ្នំនោះមានដើម
ស្វាយដ៏ធំមួយដើមដុះ
បែកមែកសាខា និងមានផ្លែទុំ
ក្រអូប គួរឱ្យចង់ញ៉ាំ។

កូនខ្លាឃ្មុំផេនដាសុភាចូលចិត្តផ្លែស្វាយណាស់។ «ក្លិនផ្លែស្វាយក្រអូបណាស់ម៉ែ!
ខ្ញុំអាចទៅបេះវានៅលើភ្នំបានទេម៉ែ? ខ្ញុំពិតជាចង់ញ៉ាំស្វាយទុំណាស់»។



ម្ដាយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង «កុំនិយាយដូច្នេះ! កូនមានដឹងទេថានៅតាមផ្លូវកាត់ព្រៃទៅភ្នំនោះមានចចកកាចសាហាវណាស់! ឯងមិនខ្លាចទេឬដែលហ៊ានទៅទីនោះ?»។

«អឺ...ប៉ុន្តែខ្ញុំជិះកង់របស់ប្អូនស្រីសុភីឱ្យលឿន នោះចចកមិនអាចចាប់ខ្ញុំបានទេ ហើយខ្ញុំបានសន្យាជាមួយប្អូនស្រីសុភីថានឹងយកផ្លែស្វាយខ្លះផ្ញើនាង»។

ឪពុកនិយាយថា «ល្អ! ផេនដាសុភា បើអ៊ុំចឹងឯងដាច់ខាតត្រូវត្រឡប់មកផ្ទះវិញឱ្យបានមុនពេលមេឃងងឹតណាកូន!»។





«កូនទៅសុខសប្បាយតាមផ្លូវណ៎ា!»
ឪពុក ម្ដាយ និងសុភីឈរគ្រវីដៃលាផេនដាសុភា
«រីងៗ... ខ្ញុំលាសិនហើយ! ជួបគ្នាពេលក្រោយ»។

ផេនដាសុភាបានជិះកង់ទៅយ៉ាងលឿនចូលព្រៃ កាត់វាលយ៉ាងរហ័ស។ កង្កែបឈ្មោះអូកៗ ដែលកំពុងដេកថ្ងៃនៅក្បែរផ្លូវភ្ញាក់ព្រើត ក្រឡាប់ផ្កាប់ផ្ងារបីជុំដួលប៉ះក្បាលនឹងដី។ «ខ្ញុំមានអារម្មណ៍សប្បាយមែន! ចចកមានអ្វីគួរឱ្យខ្លាច ខ្ញុំលឿនណាស់ៗ»។







នៅពេលនោះដែរ ចចកបានឡើងលើផ្ទាំងថ្មឆ្លុះកែវយឺតរកមើលសត្វជាចំណីដូចរាល់ដង។ «អីយ៉ា! នរណាគេនេះ? យើងមិនដែលឃើញនរណារត់លឿនយ៉ាងនេះទេ»។ «តាមពិតខ្លាឃ្មុំផេនដាសុភាជិះកង់ទេតើ!...អាមួយនេះមើលទៅទំនងដូចជាឆ្ងាញ់មាត់ណាស់។ បើប្រសិនបានញ៉ាំអាខ្លាឃ្មុំផេនដាសុភានេះប្រហែលឆ្អែតបានមួយខែ តើធ្វើដូចម្ដេចដើម្បីចាប់វាឱ្យបាន?»។ ចចកបាននឹកឃើញគំនិតល្អមួយ។

«ហេសៗហេ! ទោះបីជាឯងលឿនប៉ុណ្ណាក៏ដោយ ក៏ឯងមិនអាចឈ្នះយើងបានឡើយ»។ ចចកក៏ប្រញាប់យកប៉ែលជីករណ្តៅធំមួយនៅកណ្តាលផ្លូវ។ «ហាហាហា! តែប៉ុណ្ណេះបានហើយ» ចចកក៏ទៅពួនចាំនៅគុម្ពោតព្រៃបណ្តើរ ស្រក់ទឹកមាត់បណ្តើរ។



«ឌឹប!» នៅពេលនោះខ្លាឃ្មុំធំមួយទៀតដែលប្រញាប់ឆ្លងផ្លូវ
បានធ្លាក់ចូលក្នុងរណ្ដៅចចកជីក។
«អូយ...! ឈឺណាស់ៗ»



បន្តិចក្រោយមកផេនដាសុភាក៏បានជិះកង់ក្រហមកាត់លើខ្លាឃ្មុំធំនៅក្នុងរណ្ដៅ
ដែលកំពុងតែអង្អែលកន្លែងឈឺ «រឹង!»។

បន្ទាប់ពីឮសូរធ្លាក់យ៉ាងខ្លាំង ចចកបានចេញមកមើល ពេលនោះខ្លាឃ្មុំធំបានវាយចចក «គឺឯងហ្នឹងឬដែលជាអ្នកជីករណ្ដៅនៅទីនេះ?»។ ចំណែកឯកូនខ្លាឃ្មុំផេនដាសុភាពុំបានដឹងថាចចកជីករណ្ដៅដ៏ធំនេះទេ។



«ហាស់ ហាយ! ខ្ញុំមកដល់ហើយ»។ កូនខ្លាឃ្មុំផេនដាសុភា
បានព្យាយាមហក់ឡើងដើមស្វាយម្តងហើយម្តងទៀត។
«មួយ ពីរ បី!ឱឹប!»។ «មួយ ពីរ បី! ឱឹប!»។
ទោះបីជាកូនខ្លាឃ្មុំផេនដាសុភាខំឡើង
ប៉ុន្មានដងក៏ដោយ ក៏នៅតែធ្លាក់ពី
លើដើមស្វាយដដែល។ ពេល
នោះវាឮសំឡេងសើចពីណាមក....
«ហា! ហា ហា..!»។





«កូនខ្លាឃ្មុំឯងមិនចេះឡើងដើមឈើទេ បើឯងមិនចេះទេទ្រាំញុំផ្លែស្វាយដង្កូវស៊ី ដែលជ្រុះនឹងដីទៅ!»។ មានស្វាមួយបានចុះពីលើដើមឈើយ៉ាងស្រួល។ កូនខ្លាឃ្មុំផេនដាសុភាហាក់ដូចជាចង់យំ។ «បងស្វាឯងពិតជាអស្ចារ្យមែន ពូកែឡើងដើមឈើណាស់»។ រំពេចនោះស្វាក្រឡេកទៅឃើញកង់ របស់កូនខ្លាឃ្មុំផេនដាសុភា «ហេ! កូនខ្លាឃ្មុំ ឯងឱ្យខ្ញុំខ្ចីកង់ក្រហម ហ្នឹងជិះសិនបានទេ? ប្រសិនបើឯងឱ្យខ្ញុំខ្ចី ខ្ញុំនឹងបង្ហាត់ឯងឱ្យ ចេះឡើងដើមឈើ»។ «បានមិនថ្វីទេ» «ប៉ុន្តែបងស្វាឯង ត្រូវតែសងមកខ្ញុំវិញមុនថ្ងៃលិចណា! ព្រោះខ្ញុំត្រូវ ត្រឡប់ទៅផ្ទះវិញឆ្លងកាត់ព្រៃដែលមានចចក រស់នៅ»។









កូនខ្លាឃ្មុំផេនដាសុភាបានឡើងដើមស្វាយ ហើយញ៉ាំផ្លែស្វាយពណ៌លឿងយ៉ាងឆ្ងាញ់រហូតដល់ឆ្អែត រួចក៏បានបេះផ្លែស្វាយធំៗចំនួនដប់ពីរផ្លែថែមទៀតទម្លាក់ទៅលើស្មៅដើម្បីយកទៅផ្ញើអ្នកផ្ទះ។

«មើលទៅគួរឱ្យឆ្ងាញ់ណាស់! អ្នកទាំងអស់គ្នាប្រាកដជាសប្បាយចិត្តហើយ តែមិនទាន់ឃើញបងស្វាត្រឡប់មកវិញសោះ។ ចាំដល់ល្ងាចហើយនៅតែមិនឃើញបងស្វាត្រឡប់មកវិញទៀត។ មិនដឹងធ្វើដូចម្ដេចទេ ខ្ញុំមិនគួរឱ្យបងស្វាខ្ជីកង់សោះ»។

ភ្លាមនោះស្រាប់តែឃើញបងគោចេញមក។ «អុមម៉! មានរឿងអីកូនខ្លាឃ្មុំផេនដា បើមិនប្រញាប់ត្រឡប់ទៅផ្ទះវិញទេ មេឃនឹងងងឹតហើយ ភ្នំខ្លាឃ្មុំផេនដាសុភាឯងនៅឆ្ងាយណាស់»។

កូនខ្លាឃ្មុំផេនដាសុភាបានប្រាប់ពីមូលហេតុ។

គោក៏និយាយថា «បើអ៊ីចឹងចាំខ្ញុំនាំទៅតាមផ្លូវកាត់មិនមានចចក រួចជូនឱ្យដល់ក្បែរភ្នំរបស់ខ្លាឃ្មុំផេនដាសុភាឯង»។





«អុមម៉! ផ្លែស្វាយរបស់ឯងមើលទៅពិតជាឆ្ងាញ់ណាស់»។ ផេនដាសុភាឆ្លើយ «បាទមែនហើយ»។ គោនិយាយ «ចេះឡើងដើម ឈើពិតជាល្អមែន ខ្ញុំមិនចេះឡើងដើមឈើ និងមិនធ្លាប់ញុាំផ្លែស្វាយឆ្ងាញ់ម្តងណាទេ ញុាំបានតែផ្លែស្អុយៗធ្លាក់មកដី»។ ផេនដាសុភាសួរ «បងគោក៏មិនចេះឡើងដើមឈើដែរ?» ។



គោនិយាយ «ខ្ញុំជូនមកបានត្រឹមនេះទេ
ឆ្លងស្ទឹងនេះរួចដើរបន្តិចទៅដល់ភ្នំខ្លាឃ្មុំផេនដាសុភាឯងហើយ»។
ផេនសុភាដានិយាយ «អរគុណហើយ ដែលបានជួយខ្ញុំ ខ្ញុំនឹងរកកន្លែងទឹករាក់ៗដើរឆ្លងទៅត្រើយ
ម្ខាងទៀត បងគោញ៉ាំផ្លែស្វាយខ្លះទេ?»។ គោនិយាយ «ពិតមែនឬ? ខ្ញុំចង់ញ៉ាំវាមែនទែន»
«ហ៊ឹមៗ ឆ្ងាញ់ណាស់ៗ អុមម៉»  តែមួយភ្លែតគោញ៉ាំផ្លែស្វាយអស់ប្រាំពីរផ្លែ។
ផេនដាសុភាថ្ងូរ «បងគោញ៉ាំអស់ច្រើនណាស់!»។ បន្ទាប់ពីគោចេញបាត់
ផេនដាសុភាមានអារម្មណ៍ក្រៀមក្រំ។





«ខ្ញុំត្រូវធ្វើដូចម្ដេចទៅ មេឃជិតងងឹតហើយ ខ្ញុំមិនអាចហែលឆ្លងស្ទឹងបានទេ..»។ ស្រាប់តែឮសំឡេង «ស៊ីបៗ» អណ្ដើក៤បានអើតកពីទឹកស្ទឹង។ «ហេ! ខ្លាឃ្មុំផេនដាសុភា ផ្លែស្វាយឯងមើលទៅឆ្ងាញ់ណាស់!»



«ប្រសិនជាឱ្យយើងម្នាក់មួយផ្លែៗ ពួកយើងនឹងចម្លងឯងទៅត្រើយម្ខាងទៀត»។

«ហេសៗ ហេ! ១ ២ ៣ ៤ អូច្រើនគ្នាណាស់»។

កូនខ្លាឃ្មុំផេនដាសុភាបានដកដង្ហើមធំដោយមិនដឹងខ្លួន។



អណ្ដើកញុាំផ្លែស្វាយយ៉ាងឆ្ងាញ់មាត់ ពិតជាឆ្ងាញ់មែន! «ខ្ញុំមិនដែលបានញុាំ
ផ្លែស្វាយឆ្ងាញ់អ៊ីចឹងទេ! ពួកយើងក៏មិនដែលបានញុាំផ្លែស្វាយឆ្ងាញ់ដូចនេះដែរ!
ពិតមែនហើយ»។ ផេនដាសុភាក៏ជិះខ្នងអណ្ដើក ឆ្លងស្ទឹងទៅត្រើយម្ខាងទៀត។

«ឥឡូវនេះនៅសល់ផ្លែស្វាយតែមួយទេ មួយនេះត្រូវទុកឱ្យប្អូនស្រីសុភី»។ ស្រាប់តែឮសូរ«អូយៗ!» «អូ! ទន្សាយមានរឿងអ្វី?»។ «ខ្ញុំក្តៅខ្លួនខ្លាំងតាំងពីម្សិលមិញ មិនទាន់បានញុំាអ្វីទេ ស្រេកទឹកណាស់»។ ទន្សាយដែលមានមុខឡើងក្រហមដូចជាកំពុងក្តៅខ្លួនមែននោះ ខំសម្លឹងមើលផ្លែស្វាយដែលផេនដាសុភាកំពុងកាន់ក្នុងដៃ។ ឃើញដូច្នោះផេនដាសុភាក៏និយាយថា «ផ្លែស្វាយមួយនេះទុកឱ្យសុភីទេ»។ ផេនដាសុភាដើរទៅមុខទៀតយ៉ាងលឿន។





«ទេ! ខ្ញុំគួរតែឱ្យផ្លែស្វាយនេះទៅទន្សាយ»។ សុភាងក់ក្បាល ហើយដើរត្រឡប់ក្រោយវិញ។ «ទន្សាយខ្ញុំឱ្យឯងញ៉ាំឱ្យឆាប់ជាមានកម្លាំងវិញណ៎ា»។ «អរគុណផេនដាសុភា» ទន្សាយឈប់យំ រួចញញឹមស្រស់ស្រាយឡើងវិញ។





«ខ្ញុំមកវិញហើយ»  ពេលផេនដាសុភាមកដល់ផ្ទះវិញ មេឃក៏ងងឹតឈឹង។ ម្ដាយឪបផេនដាសុភាយ៉ាងស្ងិត «ល្អហើយ! ទីបំផុតកូនត្រឡប់ មកដល់វិញដោយសុវត្ថិភាព ផេនដាសុភាដឹងទេថាម្នាក់ៗបារម្ភពីកូនខ្លាំងណាស់»។ «ប៉ុន្តែសូម្បីតែស្វាយមួយផ្លែក៏ខ្ញុំយកមកមិនបានដែរ»។ ឪពុកយកដៃដ៏ធំទះស្មាផេនដាសុភាថ្នមៗ «មិនថ្វីទេឱ្យតែកូនបានមកដល់ផ្ទះវិញដោយសុវត្ថិភាព»។ សុភីសួរទៅបង «កង់ក្រហមនៅឯណា?» ផេនដាសុភាឆ្លើយ «កង់ហ្នឹង?.....»









វីងៗ! ស្រាប់តែឮសំឡេងកណ្ដឹងកង់ ទាំងអស់គ្នាភ្ញាក់ផ្អើលឃើញស្វាកំពុងឈរ និយាយដកដង្ហើមស្ទើរមិនដល់គ្នា។ «ផេនជាសុភា ខ្ញុំសុំទោសដែលសងកង់វិញមិនទាន់ពេលកំណត់ កង់នេះពិតជាលឿនមែន ជិះៗមិនដឹងខ្លួនស្រាប់តែដល់ កន្លែងដ៏ឆ្ងាយ»។ ស្វាបានបេះផ្លែស្វាយធំៗ ដាក់ពេញកន្ត្រកកង់របស់ផេនជាសុភា។

«អរគុណ បងស្វា!» «ខ្ញុំទេដែលត្រូវអរគុណបង!»។

បន្ទាប់ពីញ៉ាំអាហារល្ងាចហើយ  អ្នកទាំងអស់គ្នានាំគ្នាញ៉ាំផ្លែស្វាយ។ សុភីញ៉ាំអស់ពីរផ្លែម្ដាយអស់ពីរផ្លែ ឪពុកអស់បីផ្លែ និងផេនដាសុភាអស់ប្រាំផ្លែពីព្រោះផេនដាសុភាឃ្លានពេក បន្ទាប់ពីដំណើរផ្សងព្រេង។ ផ្លែស្វាយនេះពិតជាមានរសជាតិឆ្ងាញ់ណាស់ រហូតចង់ឱ្យអ្នកទាំងអស់គ្នាសាកល្បងភ្លក់ដែរ។



# រឿង ដំណើរផ្សេងព្រេងរបស់ ផេនដាសុភា

និពន្ធដោយ លោក តាជីម៉ា ស៊ីនជី

បកប្រែជាភាសាខ្មែរដោយ លោក ជា ផល និងបុគ្គលិកអង្គការសន្តិស្ម័គ្រចិត្ត(SVA)

គូររូបដោយ លោក សេង វិសាល

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០១៦



*Move forward, hand in hand.*

Shanti Volunteer Associantion

*Stand with people in need around the world.*

9 789924 905806